**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:២៥២....សហវ.....

លិខិតចូល
ថ្ងៃទី០៤....ខែកញ្ញា ឆ្នាំ2008

# ប្រកាស
## ស្តីពី
## ការបង្កើតការិយាល័យសវនកម្មកិច្ចលទ្ធកម្ម
## នៃនាយកដ្ឋានលទ្ធកម្មសាធារណៈ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/001 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញ ប្រកាសលេខ ១៤៣ សហវ.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃនាយកដ្ឋានលទ្ធកម្មសាធារណៈ

- បានឃើញ ប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** ត្រូវបានបង្កើតបន្ថែមការិយាល័យសវនកម្មកិច្ចលទ្ធកម្ម ស្ថិតនៅក្រោមនាយកដ្ឋានលទ្ធកម្មសាធារណៈ ។ ការិយាល័យសវនកម្មកិច្ចលទ្ធកម្ម ត្រូវបានបង្កើតឡើងដើម្បីតម្រង់ទិសការអនុវត្តន៍កិច្ចលទ្ធកម្ម អោយមានភាពច្បាស់លាស់ ត្រឹមត្រូវតាមវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្ម ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ក្នុងគោលបំណងទប់ស្កាត់រាល់ភាពអសកម្មក្នុងកិច្ចលទ្ធកម្មសាធារណៈ និងធានាបាននូវការទទួលខុសត្រូវខ្ពស់របស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

**ប្រការ ២:** តួនាទី និង ភារកិច្ចរបស់ការិយាល័យសវនកម្មកិច្ចលទ្ធកម្ម មានដូចខាងក្រោម ÷

- ធ្វើសវនកម្មលើរាល់កិច្ចលទ្ធកម្មដែលស្ថិតក្នុងក្របខ័ណ្ឌសហវិជ្ជាការកិច្ចលទ្ធកម្មសាធារណៈនៃបណ្តាក្រសួង-ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល និងស្ថាប័នផ្សេងទៀតដែលរដ្ឋគ្រប់គ្រង ដូចខាងក្រោម:
  + ធ្វើសវនកម្មលើរាល់កិច្ចលទ្ធកម្មដែលបានអនុវត្តរួចហើយ សំដៅរកអោយឃើញ និងកែលំអឡើងវិញនូវចំណុចអសកម្មនានា ដើម្បីឈានទៅរកកិច្ចលទ្ធកម្មសាធារណៈប្រកបដោយតម្លាភាព សមភាព ការប្រកួតប្រជែងពេញលេញ គណនេយ្យភាព និងមានប្រសិទ្ធភាពខ្ពស់ក្នុងការសន្សំសំចៃថវិការដ្ឋ
  + ធ្វើសវនកម្មលើការអនុវត្តន៍វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់ស្ថាប័នអនុវត្តន៍លទ្ធកម្ម
  + ធ្វើសវនកម្មលើឯកសារនៃការវាយតម្លៃប្រគល់កិច្ចសន្យារបស់ស្ថាប័នអនុវត្តលទ្ធកម្ម
  + ធ្វើសវនកម្មលើលទ្ធផលប្រគល់-ទទួលទំនិញ សំណង់ និង សេវា
  + ប្រមូលទិន្នន័យពាក់ព័ន្ធ ត្រួតពិនិត្យរបាយការណ៍លទ្ធកម្មប្រចាំខែ ដោយធ្វើការវាយតម្លៃ និងបូកសរុប ដើម្បីកំណត់អោយបាននូវចំណុចខ្វះខាតនៃការអនុវត្តន៍លទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
  + លើកឡើងនូវរាល់កំហុសឆ្គងក្នុងការអនុវត្តន៍ផែនការលទ្ធកម្ម និងការអនុវត្តន៍កិច្ចលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ជូនប្រធាននាយកដ្ឋានដើម្បីចាត់វិធានការកែលំអបានទាន់ពេលវេលា
- ធ្វើរបាយការណ៍ជាប្រចាំចំពោះរាល់ការចុះធ្វើសវនកម្មកិច្ចលទ្ធកម្មលើស្ថាប័នអនុវត្តលទ្ធកម្ម ដាក់ជូនប្រធាននាយកដ្ឋានដើម្បីពិនិត្យ សំរេច ។ ក្នុងករណីចាំបាច់ ប្រធាននាយកដ្ឋានត្រូវលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងដើម្បីសុំអនុសាសន៍ណែនាំអនុវត្ត

- ទទួលពាក្យបណ្តឹងតវ៉ាអំពីកិច្ចលទ្ធកម្ម និងធ្វើការវិភាគលើបណ្តឹងទាំងនោះ ហើយលើកយោបល់ជូនប្រធាននាយកដ្ឋានដើម្បីពិនិត្យ សំរេច ។ ក្នុងករណីចាំបាច់ ប្រធាននាយកដ្ឋានត្រូវលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងដើម្បីសុំអនុសាសន៍ណែនាំអនុវត្ត ។

**ប្រការ ៣:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៨

គាត ឈន់

***កន្លែងទទួល:***
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- ក្រសួង-ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល
- នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ